**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ...០១០.....សហវ.ពដ

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០០៨

# សេចក្តីជូនដំណឹង

## ស្តីពី

## បែបបទបង់ប្រាក់ពន្ធ-អាករនានាសម្រាប់អ្នកជាប់ពន្ធមធ្យមនៅតាមសាខាពន្ធដារខេត្ត-ក្រុង

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុមានកិត្តិយសសូមជំរាបជូនដំណឹងដល់លោក/លោកស្រី ដែលជាបណ្ណាធិការ ឬកម្មសិទ្ធិករ សហគ្រាស ក្រុមហ៊ុនទាំងអស់ឱ្យបានជ្រាបថា: ចាប់ពីខែតុលា ឆ្នាំ២០០៤ រហូតមក សហគ្រាស ក្រុមហ៊ុន ដែលជាអ្នកជាប់ពន្ធស្ថិតក្រោមការគ្រប់គ្រងរបស់អង្គភាពគ្រប់គ្រងអ្នកជាប់ពន្ធមធ្យម នៃការិយាល័យគ្រប់គ្រងអ្នកជាប់ពន្ធធំ និងមធ្យម នៅរាជធានីភ្នំពេញ បានធ្វើការបង់ប្រាក់ពន្ធ-អាករនានានៅធនាគារជាតិ នៃកម្ពុជា ។

អនុវត្តតាមកម្មវិធីកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ក្នុងទិសដៅពង្រីកការប្រមូលពន្ធគ្រប់ប្រភេទតាមរយៈធនាគារជាតិនៃកម្ពុជា ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមជំរាបជូនលោក/លោកស្រី ដែលជាបណ្ណាធិការ ឬកម្មសិទ្ធិករ សហគ្រាសក្រុមហ៊ុនទាំងអស់ ដែលស្ថិតក្រោមរបបគ្រប់គ្រងអ្នកជាប់ពន្ធមធ្យម នៃរបបស្វ័យប្រកាសនៅគ្រប់ខេត្ត-ក្រុង ត្រូវបង់ផ្ទាល់នៅធនាគារជាតិនៃកម្ពុជា ខេត្ត-ក្រុង ចាប់ពីថ្ងៃទី ០២ ខែឧសភា ឆ្នាំ ២០០៨ តទៅ ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមកំណត់នូវបែបបទនៃការបង់ប្រាក់ពន្ធ-អាករនានារបស់សហគ្រាស ក្រុមហ៊ុន និង កម្មសិទ្ធិករទាំងអស់ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់សាខាពន្ធដារខេត្ត-ក្រុង ដូចខាងក្រោម :

១-ការបង់ប្រាក់ពន្ធ-អាករជាសាច់ប្រាក់ ត្រូវធ្វើដោយផ្ទាល់នៅធនាគារជាតិ នៃកម្ពុជា ខេត្ត-ក្រុង

២-ការបង់ប្រាក់ពន្ធ-អាករដោយវិធីផ្ទេរគណនីធនាគារត្រូវផ្ទេរចូលគណនី របស់សាខាពន្ធដារខេត្ត-ក្រុង ។ ចំពោះលេខគណនីដែលត្រូវផ្ទេរ សហគ្រាស ក្រុមហ៊ុន និង កម្មសិទ្ធិករ ត្រូវទៅទំនាក់ទំនងនៅសាខាពន្ធដារខេត្ត-ក្រុង ។

ក្រោយការបង់ប្រាក់ពន្ធ-អាកររួច លោក/លោកស្រីត្រូវយកបង្កាន់ដៃទទួលប្រាក់ពន្ធដែលចេញដោយធនាគារជាតិនៃកម្ពុជា ខេត្ត-ក្រុង ដោយភ្ជាប់ជាមួយនឹងលិខិតប្រកាសការពើពន្ធ ដាក់ជូនសាខាពន្ធដារខេត្ត-ក្រុង ទៅតាមកាលកំណត់ដូចមានចែងក្នុងច្បាប់ស្តីពីសារពើពន្ធ ។

អាស្រ័យដូចបានជំរាបជូនខាងលើ សូមលោក/លោកស្រី អនុវត្តតាមខ្លឹមសារនៃលិខិតជូនដំណឹងនេះឱ្យបានល្អប្រសើរ ។

...ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**គាត ឈន់**

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798